**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៩៥១ ...... សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដឹកនាំគម្រោងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយព្យុះកេតសាណា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញលិខិតលេខ ៥៥០៦ សហវ.វស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការឯកភាពលើសេចក្តីព្រាងកិច្ចព្រមព្រៀងហិរញ្ញប្បទាន សម្រាប់អនុវត្តគម្រោងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយព្យុះកេតសាណា
- យោងតាមសំណូមពរការងារចាំបាច់



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

# សម្រេច

**ប្រការ ១ :** បង្កើតគណៈកម្មាធិការដឹកនាំគម្រោង (Project Steering Committee) សម្រាប់អនុវត្តគម្រោងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយព្យុះកេតសាណា ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- | ឯកឧត្តម **ណឺ ផុង** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានទី២ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គ.ជ.គ.ម) | សមាជិក |
| ៣- | ឯកឧត្តម **សៅ ជីវ័ន្ត** | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៤- | ឯកឧត្តម **វង្សី វិស្សុត** | អគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- | ឯកឧត្តម **ពៅ សាមី** | អគ្គលេខាធិការ នៃ គ.ជ.គ.ម | សមាជិក |
| ៦- | លោក **ចាន់ សុធី** | ប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ២ :** គណៈកម្មាធិការដឹកនាំគម្រោងនេះ មានភារកិច្ចដូចខាងក្រោម:

១- ផ្តល់គោលការណ៍ណែនាំ និងទិន្នន័យចាំបាច់សំខាន់ៗដល់ក្រុមបេសកកម្មរៀបចំគម្រោងរបស់ដៃគូអភិវឌ្ឍន៍

២- ផ្តល់ការណែនាំគោលនយោបាយពាក់ព័ន្ធនឹងការអនុវត្តគម្រោង

៣- តម្រែតម្រង់ និងសម្រេចលើដំណោះស្រាយបញ្ហាពាក់ព័ន្ធនឹងការអនុវត្តគម្រោង

៤- បំពេញតួនាទីសម្របសម្រួល និងផ្តល់ការគាំទ្របច្ចេកទេស និងរដ្ឋបាលដល់ការរៀបចំ និងការអនុវត្តគម្រោង តាមការចាំបាច់

**ប្រការ ៣ :** គណៈកម្មាធិការដឹកនាំគម្រោងនេះ មានក្រុមបច្ចេកទេសជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- | ឯកឧត្តម **សៅ ជីវ័ន្ត** | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | ប្រធាន |
| ២- | ឯកឧត្តម **រស់ សុវណ្ណ** | អគ្គលេខាធិការរង នៃ គ.ជ.គ.ម | សមាជិក |
| ៣- | ឯកឧត្តម **ឡាំ អេងហួត** | ទីប្រឹក្សា នៃ គ.ជ.គ.ម | សមាជិក |
| ៤- | លោក **ឧុច សំណាង** | អគ្គនាយករង ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |

| | | | |
|---|---|---|---|
| ៥- | លោក **រស់ បរម** | អនុប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- | លោក **ថ្ងាយ ម៉ុម** | អនុប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ<br>ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧- | លោក **គួច ចំន្ទក្រីស្នា** | ប្រធានការិយាល័យធនាគារពិភពលោក<br>នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- | លោក **ឈុច បញ្ញូស៊ុខទិន** | អនុប្រធានការិយាល័យធនាគារពិភពលោក<br>នាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ ៤**: អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន អង្គភាព ពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំង សាមីខ្លួន ដូចមានចែងក្នុងប្រការ ១ និងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០១០

**គាត ឈន់**

***កន្លែងទទួល:***

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងអភិវឌ្ឍន៍ជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ការិយាល័យធនាគារពិភពលោកប្រចាំនៅកម្ពុជា
- ដូចប្រការ ១ និង ៣
- ឯកសារ-កាលប្បវត្តិ